តម្លាភាពកម្ពុជា
TRANSPARENCY INTERNATIONAL
Cambodia




# ការស្ទង់មតិថ្នាក់ជាតិស្តីពី គណនេយ្យភាព និងតម្លាភាព នៃដំណើរការថវិកា

## របាយការណ៍សង្ខេប

ខែមេសា ឆ្នាំ២០១៨

# អង្គការតម្លាភាពកម្ពុជា

អាសយដ្ឋាន៖ ផ្ទះលេខ ៣ ផ្លូវលេខ ៣៩០ សង្កាត់បឹងកេងកង ៣
ខណ្ឌចំការមន, ១២៣០៤, រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ៖ (+៨៥៥) ២៣ ២១៤ ៤៣០ / (+៨៥៥) ២៣ ២១៤ ២១១

គេហទំព័រក្នុងប្រទេស៖ www.ticambodia.org
គេហទំព័រនៅការិយាល័យកណ្តាល៖ www.transparency.org

តម្លាភាពកម្ពុជា
TRANSPARENCY INTERNATIONAL
Cambodia

អង្គការតម្លាភាពកម្ពុជា គឺជាសាខាក្នុងប្រទេសមួយដែលមានការទទួលស្គាល់ពេញលេញរបស់អង្គការតម្លាភាពអន្តរជាតិ និងត្រូវបានបង្កើតឡើងជាផ្លូវការនៅថ្ងៃទី៥ ខែកក្កដា ឆ្នាំ២០១០ ដោយសកម្មជនប្រឆាំងអំពើពុករលួយ និងអ្នកជំនាញជាច្រើន ដែលប្តេជ្ញាបង្កើតសង្គមកម្ពុជាប្រកបដោយតម្លាភាព និងគណនេយ្យភាព។ ចាប់ពីពេលនោះមក អង្គការនេះបានបង្កើតជាស្ថាប័នដ៏រឹងមាំមួយ ដែលប្រយុទ្ធប្រឆាំងអំពើពុករលួយ និងលើកកម្ពស់សុចរិតភាព តម្លាភាព និងគណនេយ្យភាពក្នុងប្រទេស។

យើងធ្វើការជាមួយបុគ្គល និងស្ថាប័នជាច្រើននៅគ្រប់កម្រិត ដូចជា រដ្ឋាភិបាល សង្គមស៊ីវិល អាជីវកម្ម ប្រព័ន្ធផ្សព្វផ្សាយ និងសាធារណជន ដើម្បីសម្រេចបានការអភិវឌ្ឍសេដ្ឋកិច្ចប្រកបដោយនិរន្តរភាព លើកកម្ពស់សុចរិតភាព និងប្រឆាំងអំពើពុករលួយ។

**© ២០១៨ អង្គការតម្លាភាពកម្ពុជា។ សិទ្ធិគ្រប់បែបយ៉ាង។**

រាល់ខ្លឹមសារនៅក្នុងឯកសារនេះពុំឆ្លុះបញ្ចាំងពីទស្សនៈរបស់ម្ចាស់ជំនួយឡើយ។

SWEDEN

OXFAM

១

# សេចក្តីផ្តើម

តាមរបាយការណ៍ស្រាវជ្រាវកន្លងមកបង្ហាញឱ្យឃើញថា តម្លាភាព និងគណនេយ្យភាពថវិកានៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិក្នុងប្រទេសកម្ពុជា នៅមានកម្រិតទាបនៅឡើយ។ រាជរដ្ឋាភិបាលកម្ពុជា អង្គការសង្គមស៊ីវិល នឹងសមាជិកនៃសហគមន៍អ្នកផ្តល់ជំនួយអន្តរជាតិបានស្នើឱ្យមាន និងអនុវត្តសកម្មភាពផ្តួចផ្តើមថ្មីៗជាច្រើនដែលគួរឱ្យសើ្ញចសរសើរ ដើម្បីកែលម្អស្ថានភាពនេះឱ្យប្រសើរឡើង។ ប៉ុន្តែមកដល់បច្ចុប្បន្ននេះ យើងបានដឹងតិចតួចប៉ុណ្ណោះអំពីការយល់ដឹង ឥរិយាបថ និងការអនុវត្តរបស់ប្រជាពលរដ្ឋកម្ពុជា ទាក់ទងនឹងព័ត៌មានថវិកាសាធារណៈ ដំណើរការថវិកាសាធារណៈ ក៏ដូចជាសមិទ្ធផលដែលបានពីការប្រើប្រាស់ថវិកាសាធារណៈ។ ការស្វែងយល់នូវចំណុចទាំងនេះគឺពិតជាមានសារៈសំខាន់ខ្លាំងណាស់ ដើម្បីបង្កើនការយល់ដឹង ការយកចិត្តទុកដាក់ និងការចូលរួមរបស់ប្រជាពលរដ្ឋ ដែលសុទ្ធតែជាធាតុចាំបាច់ក្នុងការធានាបាននូវតម្លាភាព និងគណនេយ្យភាពថវិកា។

ដើម្បីឆ្លើយតបចំពោះបញ្ហាដែលបានលើកឡើងខាងលើ របាយការណ៍ស្រាវជ្រាវនេះបង្ហាញនូវលទ្ធផលរកឃើញពីការស្ទង់មតិថ្នាក់ជាតិមួយ ដែលមានគោលដៅស្វែងយល់ និងប៉ាន់ប្រមាណពីការយល់ឃើញ និងឥរិយាបថរបស់ប្រជាពលរដ្ឋចំពោះតម្លាភាព និងគណនេយ្យភាពថវិកាក្នុងប្រទេសកម្ពុជា ក៏ដូចជាការយល់ដឹង និងបទពិសោធន៍របស់ពួកគាត់ ពាក់ព័ន្ធជាមួយថវិកា និងបញ្ហាថវិកាក្នុងប្រទេសកម្ពុជា។ ការស្ទង់មតិនេះត្រូវបានធ្វើឡើងក្នុងខែតុលា ឆ្នាំ ២០១៧ តាមរយៈកិច្ចសម្ភាសន៍ជាមួយមនុស្សចំនួន ១,៥៩៦ នាក់ ក្នុងភូមិចំនួន ២០០ ស្ថិតក្នុងឃុំចំនួន ១០០ នៅក្នុងរាជធានី ខេត្តទាំង ២៥ ទូទាំងប្រទេសកម្ពុជា។

ការស្ទង់មតិនេះត្រូវបានរំពឹងថា នឹងផ្តល់ជាភស្តុតាងជូនដល់ស្ថាប័នពាក់ព័ន្ធរបស់រដ្ឋាភិបាល និងអង្គការមិនមែនរដ្ឋាភិបាល ក៏ដូចជាដៃគូអភិវឌ្ឍន៍នានា ដែលមានបំណងស្វែងយល់ឱ្យស៊ីជម្រៅបន្ថែមទៀត អំពីការយល់ឃើញ និងឥរិយាបថរបស់ប្រជាពលរដ្ឋចំពោះបញ្ហាថវិកា និងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនៅក្នុងប្រទេសកម្ពុជា ទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។ ជាលទ្ធផល ចំណេះដឹងទាំងនេះអាចជួយពួកគាត់ក្នុងការបង្កើត ឬធ្វើកំណែទម្រង់គោលនយោបាយ និងកម្មវិធីនានា ដើម្បីបង្កើនតម្លាភាព និងគណនេយ្យភាពថវិកាឱ្យកាន់តែប្រសើរថែមទៀត។

ផ្នែកខាងក្រោម គឺជាការសង្ខេបនូវលទ្ធផលរកឃើញសំខាន់ៗនៃការស្ទង់មតិនេះ ដែលត្រូវបានបែងចែកជាពីរផ្នែកគឺ ការបង្ហាញទិន្នន័យនៃការស្ទង់មតិសម្រាប់ថ្នាក់ជាតិ និងថ្នាក់ឃុំសង្កាត់។ ការបែងចែងកម្រិតរដ្ឋបាលជា២ផ្នែកនេះត្រូវបានរៀបចំឡើង ដើម្បីឆ្លុះបញ្ចាំងពីប្រព័ន្ធផ្សេងគ្នានៃការគ្រប់គ្រងហិរញ្ញវត្ថុនៅថ្នាក់ក្រោមជាតិ និងថ្នាក់ជាតិ បន្ទាប់ពីការអនុវត្តដំណើរការវិមជ្ឈការ និងវិសហមជ្ឈការ ដែលត្រូវបានពង្រឹងថែមទៀតតាមរយៈច្បាប់ស្តីពី ការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឆ្នាំ២០០៨។ ហើយនេះគឺជាភាពខុសគ្នាដ៏សំខាន់ ដូចដែលបង្ហាញស្រាប់នៅក្នុងរបាយការណ៍នេះ។ បើទោះជា ចំណេះដឹងអំពីថវិការបស់រដ្ឋបាលទាំង២ថ្នាក់ខាងលើនៅមានកម្រិតក៏ដោយ កម្មវិធីវិមជ្ឈការ និងវិសហមជ្ឈការនាពេលថ្មីៗនេះ ទទួលបាននូវលទ្ធផលគួរឱ្យកត់សម្គាល់ តាមរយៈការយល់ដឹងកាន់តែប្រសើរ អំពីសិទ្ធិក្នុងការចូលរួមគ្រប់គ្រង និងធ្វើផែនការថវិកានៅថ្នាក់មូលដ្ឋានជាងនៅថ្នាក់ជាតិ។

# ២

# លទ្ធផលរកឃើញសំខាន់ៗ

## តម្លាភាព និងគណនេយ្យភាពថវិកាថ្នាក់ជាតិ

ជាទូទៅ ចំណេះដឹង និងការយល់ដឹងរបស់ប្រជាពលរដ្ឋស្តីពីដំណើរការថវិកាថ្នាក់ជាតិមានកម្រិតទាបយ៉ាងខ្លាំង។ ហើយចំណេះដឹង និងការយល់ដឹងរបស់ពួកគាត់រងឥទ្ធិពលយ៉ាងខ្លាំងដោយកត្តាសង្គមប្រជាសាស្រ្ត និងសង្គមសេដ្ឋកិច្ច រួមទាំងកត្តាយេនឌ័រ ការអប់រំ និងប្រាក់ចំណូល។

### ការយល់ដឹងអំពីដំណើរថវិកាជាតិ

**៩៩.៧%**
ប្រជាពលរដ្ឋពុំដឹងពីចំនួនសរុបនៃថវិកាជាតិរបស់ប្រទេសកម្ពុជាសម្រាប់ឆ្នាំ២០១៧ឡើយ

**៩៤.៩%**
ប្រជាពលរដ្ឋពុំដឹងថាស្ថាប័នរដ្ឋណាមួយជាអ្នករៀបចំសេចក្តីព្រាងច្បាប់ថវិកាឡើយ

**៨.៣%**
បុរសដឹងថាស្ថាប័នរដ្ឋណាមួយជាអ្នករៀបចំសេចក្តីព្រាងច្បាប់ថវិកា

**១.៩%**
ស្រ្តីដឹងថាស្ថាប័នរដ្ឋណាមួយជាអ្នករៀបចំសេចក្តីព្រាងច្បាប់ថវិកា

**២៦.៥%**
អ្នកបានទទួលការអប់រំកម្រិតក្រោយមធ្យមសិក្សាដឹងថាស្ថាប័នរដ្ឋណាមួយជាអ្នករៀបចំសេចក្តីព្រាងច្បាប់ថវិកា

**0.0%**
អ្នកដែលពុំបានទទួលការអប់រំដឹងថាស្ថាប័នរដ្ឋណាមួយជាអ្នករៀបចំសេចក្តីព្រាងច្បាប់ថវិកា

បច្ចុប្បន្ន លទ្ធភាពរបស់ប្រជាពលរដ្ឋក្នុងការទទួលបានព័ត៌មានថវិកា គឺនៅមានកម្រិតយ៉ាងខ្លាំង។ ថ្វីបើដូច្នេះក្តី ប្រជាពលរដ្ឋមានជំនឿយ៉ាងមុតមាំថា ការទទួលបានព័ត៌មានថវិកាគឺពិតជាមានសារៈសំខាន់ណាស់។ ហេតុនេះ ពួកគាត់មានការគាំទ្រយ៉ាងខ្លាំង ដើម្បីឱ្យមានការទទួលបានព័ត៌មានថវិកាកាន់តែទាន់ពេលវេលា និងមានតម្លាភាពថែមទៀត។

## ការទទួលបានព័ត៌មានថវិកាជាតិ

**៩៨.៩%**
ប្រជាពលរដ្ឋពុំដែលធ្លាប់ព្យាយាមស្វែងរកព័ត៌មានស្តីពីថវិកាជាតិឡើយ

**៩៩.៩%**
ប្រជាពលរដ្ឋពុំធ្លាប់ឃើញឯកសារថវិកាផ្លូវការណាមួយដែលរៀបចំដោយរដ្ឋាភិបាលថ្នាក់ជាតិឡើយ

**៩៧.៦%**
ប្រជាពលរដ្ឋជឿថា ព័ត៌មានថវិកាជាតិគួរតែរៀបចំឱ្យកាន់តែងាយស្រួលទទួលបាន និងងាយស្រួលយល់ សម្រាប់សាធារណជនបន្ថែមទៀត

**៨៤.៥%**
ប្រជាពលរដ្ឋជឿថា ការទទួលបាននូវព័ត៌មានស្តីពីថវិកាជាតិរបស់កម្ពុជាគឺពិតជាមានសារៈសំខាន់

ចំណែកឯ ចំណេះដឹងទាក់ទងនឹងប្រភពចំណូលថវិកាជាតិក៏មានកម្រិតទាបផងដែរ។ ហើយការយល់ដឹងអំពីកាតព្វកិច្ចរបស់ប្រជាពលរដ្ឋក្នុងការបង់ពន្ធជូនរដ្ឋ ក៏មានកម្រិតទាបផងដែរ។ បើទោះជាដូច្នេះក្តី មានការគាំទ្រច្រើនចំពោះការបង្កើនការប្រមូលពន្ធ ប្រសិនបើកំណើននៃការប្រមូលពន្ធនោះធ្វើឱ្យមានការផ្តល់សេវាសាធារណៈកាន់តែច្រើន ឬកាន់តែប្រសើរឡើង។ ប្រព័ន្ធពន្ធកើន (Progressive system of taxation) ក៏ត្រូវបានគាំទ្រដោយអ្នកផ្តល់ចម្លើយភាគច្រើនផងដែរ មានន័យថា អ្នករកចំណូលបានកាន់តែច្រើនត្រូវបង់ពន្ធកាន់តែខ្ពស់។

## ការយល់ដឹងអំពីប្រភពនៃថវិកាជាតិ

**៣៣.៤%**
ប្រជាពលរដ្ឋពុំដឹងអំពីប្រភពចំណូលថវិកាជាតិសោះឡើយ

**៦១.០%**
ប្រជាពលរដ្ឋយល់ស្របក្នុងការបង់ពន្ធខ្ពស់ជាងមុន ប្រសិនបើការបង់ពន្ធនោះនឹងធ្វើឱ្យសេវាដែលផ្តល់ដោយរដ្ឋាភិបាលមានចំនួនកាន់តែច្រើនឬមានគុណភាពកាន់តែប្រសើរជាងនេះ

**៦៥.៤%**
ប្រជាពលរដ្ឋយល់ស្របថា បុគ្គលដែលមានទ្រព្យសម្បត្តិ និងចំណូលកាន់តែច្រើន គួរតែបង់ពន្ធកាន់តែខ្ពស់

**៨១.០%**
ប្រជាពលរដ្ឋពុំបានដឹងថា ខ្លួនមានជាប់កាតព្វកិច្ចត្រូវបង់ពន្ធណាមួយជូនរដ្ឋសោះឡើយ

បើធៀបនឹងកង្វះខាតចំណេះដឹង ការយល់ដឹង និងព័ត៌មានច្បាស់លាស់អំពីដំណើរការថវិកាជាតិ ការចូលរួមរបស់សាធារណជនក៏មានកម្រិតទាបផងដែរ។ ទោះជាយ៉ាងនេះក្តី មានការគាំទ្រយ៉ាងខ្លាំងក្នុងចំណោមប្រជាពលរដ្ឋ ដើម្បីឱ្យមានកម្រិតនៃការចូលរួមកាន់តែខ្ពស់។ ការចូលរួមរបស់សាធារណជននៅក្នុងដំណើរការថវិកាជាតិត្រូវបានមើលឃើញថា ជាមធ្យោបាយដើម្បីបង្កើនប្រសិទ្ធភាព និងគុណភាពនៃគម្រោង និងសេវាសាធារណៈ។

## ការយល់ឃើញទាក់ទងនឹងការចូលរួមរបស់ប្រជាពលរដ្ឋ

**៨៩.០%** ប្រជាពលរដ្ឋជឿថា គុណភាពនៃសេវានឹងប្រសើរឡើងថែមទៀត ប្រសិនបើប្រជាពលរដ្ឋអាចចូលរួមនៅក្នុងដំណើរការថវិកាជាតិ

**៨៧.៨%** ប្រជាពលរដ្ឋជឿថា ថវិកាជាតិនឹងឆ្លើយតបកាន់តែប្រសើរនូវតម្រូវការពិតប្រាកដរបស់ប្រជាពលរដ្ឋ ប្រសិនបើពួកគាត់អាចចូលរួមក្នុងដំណើរការថវិកាជាតិ

អ្នកផ្តល់ចម្លើយពុំអាចវែកញែកឱ្យច្បាស់លាស់រវាងរដ្ឋាភិបាល និងនយោបាយរបស់គណបក្សឡើយ ដែលជារឿយៗអ្នកផ្តល់ចម្លើយមិនដឹងប្រាកដរវាងគម្រោងអភិវឌ្ឍដែលទទួលថវិការបស់រដ្ឋ និងគម្រោងអភិវឌ្ឍដែលទទួលថវិការបស់គណបក្សនយោបាយ។ អ្នកផ្តល់ចម្លើយភាគច្រើនធ្លាប់ដឹងឮអំពីករណីពាក់ព័ន្ធនឹងការសន្យាផ្តល់ថវិកាជួយគម្រោងអភិវឌ្ឍ ដើម្បីដោះដូរជាមួយការគាំទ្រផ្នែកនយោបាយ។

## ការយល់ឃើញទាក់ទងនឹងថវិកាសម្រាប់គម្រោងអភិវឌ្ឍ

**៦០.៧%**

ប្រជាពលរដ្ឋធ្លាប់បានឮ/ប្រទះផ្ទាល់នូវករណីដែលគម្រោងអភិវឌ្ឍមួយត្រូវបានសន្យាផ្តល់ជូន ជាថ្នូរនឹងការគាំទ្រផ្នែកនយោបាយ

**៤១.០%**

ប្រជាពលរដ្ឋពុំអាចវែកញែកឱ្យច្បាស់រវាងគម្រោងអភិវឌ្ឍដែលឧបត្ថម្ភដោយថវិការបស់រដ្ឋ និងគម្រោងអភិវឌ្ឍដែលឧបត្ថម្ភដោយថវិការបស់គណបក្សនយោបាយ

# តម្លាភាព និងគណនេយ្យភាពថវិកាថ្នាក់ឃុំ សង្កាត់

ខណៈដែលចំណេះដឹង និងការយល់ដឹងរបស់ប្រជាពលរដ្ឋអំពីដំណើរការថវិកានៅថ្នាក់ឃុំ សង្កាត់ មានកម្រិតទាប ប៉ុន្តែជាទូទៅគឺមានកម្រិតខ្ពស់ជាងនៅថ្នាក់ជាតិ។ ហើយ កម្រិតនៃចំណេះដឹងនេះរងឥទ្ធិពលយ៉ាងខ្លាំងដោយកត្តាសង្គមប្រជាសាស្ត្រ និងសង្គមសេដ្ឋកិច្ចផងដែរ។

## ការយល់ដឹងអំពីដំណើរការថវិកាឃុំ សង្កាត់

**៦២.៥%**

ប្រជាពលរដ្ឋពុំដឹងថា នរណាជាអ្នកទទួលខុសត្រូវចំបងក្នុងការរៀបចំថវិកាឃុំ សង្កាត់ឡើយ

**៥៣.៦%**

បុរសពុំដឹងថា នរណាជាអ្នកទទួលខុសត្រូវចំបងក្នុងការរៀបចំថវិកាឃុំ សង្កាត់ ឬនរណាជាអ្នកត្រួតពិនិត្យ និងអនុម័តថវិកាឃុំ សង្កាត់ឡើយ

**៦២.៤%**

ស្ត្រីពុំដឹងថា នរណាជាអ្នកទទួលខុសត្រូវចំបងក្នុងការរៀបចំថវិកាឃុំ សង្កាត់ ឬនរណាជាអ្នកត្រួតពិនិត្យ និងអនុម័តថវិកាឃុំ សង្កាត់ឡើយ

**៣៦.៧%**

ប្រជាពលរដ្ឋដែលទទួលបានការអប់រំកម្រិតក្រោយមធ្យមសិក្សាដឹងថា នរណាជាអ្នកទទួលខុសត្រូវចំបងក្នុងការរៀបចំថវិកាឃុំ សង្កាត់ ឬនរណាជាអ្នកត្រួតពិនិត្យ និងអនុម័តថវិកាឃុំ សង្កាត់ឡើយ

**១៦.១%**

ប្រជាពលរដ្ឋដែលពុំទទួលបានការអប់រំដឹងថា នរណាជាអ្នកទទួលខុសត្រូវចំបងក្នុងការរៀបចំថវិកាឃុំ សង្កាត់ ឬនរណាជាអ្នកត្រួតពិនិត្យ និងអនុម័តថវិកាឃុំ សង្កាត់ឡើយ

ចំណែកឯ ចំណេះដឹងអំពីប្រភពនៃចំណូលថវិកាឃុំ សង្កាត់ក៏មានកម្រិតទាបផងដែរ ដោយអ្នកផ្តល់ចម្លើយភាគច្រើនមិនដឹងពីប្រភពនៃចំណូលថវិកាឃុំ សង្កាត់សោះឡើយ។ យ៉ាងណាក៏ដោយ ជាទូទៅ អ្នកផ្តល់ចម្លើយជឿថា ថវិកាដែលក្រុមប្រឹក្សាឃុំ សង្កាត់ទទួលបាន គឺមិនទាន់គ្រប់គ្រាន់នោះទេ។ ប្រជាពលរដ្ឋភាគច្រើនគាំទ្រឱ្យបង្កើនថវិកាឃុំ សង្កាត់ ដើម្បីឆ្លើយតបនឹងកង្វះខាតនេះ។

## ការយល់ឃើញទាក់ទងនឹងថវិកាឃុំ សង្កាត់

**៣៦.៧%**

ប្រជាពលរដ្ឋពុំដឹងពីប្រភពនៃចំណូលថវិកាឃុំ សង្កាត់សោះឡើយ

**៤២.៥%**

ប្រជាពលរដ្ឋជឿថា ថវិកាដែលមានសម្រាប់ក្រុមប្រឹក្សាឃុំ សង្កាត់ គឺមិនទាន់គ្រប់គ្រាន់ដើម្បីចំណាយលើថ្លៃរដ្ឋបាល គម្រោងអភិវឌ្ឍន៍ និងសេវានានាដែលចាំបាច់ក្នុងមូលដ្ឋានរបស់ពួកគាត់

**៦៦.៣%**

ប្រជាពលរដ្ឋជឿថា ឃុំ សង្កាត់គួរទទួលបានថវិកាច្រើនជាងនេះពីរដ្ឋាភិបាលថ្នាក់ជាតិ

ប្រជាពលរដ្ឋក៏បានបង្ហាញនូវការយល់ដឹងច្រើនអំពីសិទ្ធិរបស់ពួកគាត់ក្នុងការចូលរួមក្នុងដំណាក់កាលផ្សេងៗនៃការធ្វើផែនការថវិកាឃុំ សង្កាត់ និងការអនុវត្តសកម្មភាពផងដែរ។ ថ្វីបើដូច្នេះក្តី តាមបទពិសោធន៍កន្លងមក ការចូលរួមនៅក្នុងដំណាក់កាលផ្សេងៗនៃការធ្វើផែនការថវិកាឃុំ សង្កាត់ និងការអនុវត្តសកម្មភាព គឺមានកម្រិតទាប។ កម្រិតនៃការចូលរួមត្រូវបានរងឥទ្ធិពលជាពិសេសដោយកត្តាអាយុ។

## កម្រិតនៃការចូលរួមរបស់ប្រជាពលរដ្ឋក្នុងដំណើរការថវិកាឃុំ សង្កាត់

**៨៥.១%**

ប្រជាពលរដ្ឋ ដឹងអំពីសិទ្ធិក្នុងការចូលរួមកិច្ចប្រជុំប្រចាំឆ្នាំស្តីពីការធ្វើផែនការអភិវឌ្ឍកម្ម វិធីវិនិយោគ និងថវិកាឃុំ សង្កាត់ជាដើម

**៨៣.៤%**

ប្រជាពលរដ្ឋដែលមានអាយុ១៨-២៧ឆ្នាំ មិនធ្លាប់បានចូលរួមក្នុងដំណើរការថវិកាណាមួយរបស់ឃុំ សង្កាត់ឡើយ

**២៨.៦%**

ប្រជាពលរដ្ឋធ្លាប់ប្រើប្រាស់សិទ្ធិក្នុងការចូលរួមកិច្ចប្រជុំប្រចាំឆ្នាំស្តីពី ការធ្វើផែនការអភិវឌ្ឍកម្មវិធីវិនិយោគ និងថវិកាឃុំ សង្កាត់នាពេលកន្លងមក

**៥៩.៣%**

ប្រជាពលរដ្ឋដែលមានអាយុលើសពី៥៨ ឆ្នាំ មិនធ្លាប់បានចូលរួមក្នុងដំណើរការថវិកាណាមួយរបស់ឃុំ សង្កាត់ឡើយ

ចំពោះការយល់ឃើញអំពីប្រសិទ្ធភាពនៃការចំណាយថវិកា ទៅលើការអនុវត្តគម្រោង និងការផ្តល់សេវាសាធារណៈរបស់ឃុំ សង្កាត់ ជាទូទៅគឺនៅមានកម្រិតទាប។ ថ្វីបើដូច្នេះក្តី ប្រជាពលរដ្ឋកម្រលើកឡើងនូវកង្វល់ទាំងអស់នេះ ឬស្វែងរកដំណោះស្រាយឡើយ។ ប្រជាពលរដ្ឋភាគច្រើនជឿថា គុណភាព និងគុណតម្លៃនឹងប្រសើរឡើងជាងនេះ នៅពេលដែលមានការចូលរួមកាន់តែច្រើនពីប្រជាពលរដ្ឋក្នុងដំណើរការថវិកា។

## ការយល់ឃើញទាក់ទងនឹងប្រសិទ្ធភាពនៃការប្រើប្រាស់ថវិកា

**២៩.៨%**

ប្រជាពលរដ្ឋជឿថា សេវា ឬគម្រោងនានាដែលក្រុមប្រឹក្សាឃុំ សង្កាត់ផ្តល់ឱ្យ ឬអនុវត្ត គឺបង្ហាញឱ្យឃើញពីប្រសិទ្ធភាពនៃការចំណាយថវិកា

**១២.៩%**

ប្រជាពលរដ្ឋធ្លាប់បានទំនាក់ទំនងទៅគណៈកម្មការគ្រប់គ្រងគម្រោង ដើម្បីលើកឡើងនូវកង្វល់ និងក្តីបារម្ភអំពីការមិនពេញចិត្តនឹងគម្រោងដែលបានបញ្ចប់រួចហើយ

**៩១.១%**

ប្រជាពលរដ្ឋជឿថា គុណភាពនៃសេវា ឬគម្រោងនានានឹងកាន់តែប្រសើរថែមទៀត ប្រសិនបើប្រជាពលរដ្ឋអាចចូលរួមកាន់តែច្រើនក្នុងដំណើរការថវិកា

លទ្ធភាពរបស់ប្រជាពលរដ្ឋក្នុងការទទួលបានព័ត៌មានថវិកាថ្នាក់ឃុំ សង្កាត់ គឺមានកម្រិតទាប ដោយប្រជាពលរដ្ឋជាច្រើនពុំបានដឹងថា ព័ត៌មានថវិកាត្រូវបានរក្សាទុកដោយក្រុមប្រឹក្សាឃុំ សង្កាត់របស់ខ្លួនឡើយ។ ប្រជាពលរដ្ឋចំនួនតិចតួចប៉ុណ្ណោះដែលធ្លាប់បានទទួលព័ត៌មានអំពីការផ្សព្វផ្សាយនូវព័ត៌មានថវិកា ហើយនិងធ្លាប់បានសាកល្បងស្វែងរកព័ត៌មាននោះ។ មានការគាំទ្រយ៉ាងខ្លាំងដើម្បីឱ្យមានលទ្ធភាពកាន់តែប្រសើរក្នុងការទទួលបានព័ត៌មានថវិកានៅថ្នាក់ឃុំ សង្កាត់ឱ្យទាន់ពេលវេលា និងមានតម្លាភាពបន្ថែមទៀត។

## ការទទួលបានព័ត៌មានថវិកាឃុំ សង្កាត់

**៩០.២%**
ប្រជាពលរដ្ឋមិនធ្លាប់បានទទួលព័ត៌មានណាមួយពីអាជ្ញាធរឃុំ សង្កាត់អំពីការផ្សព្វផ្សាយនូវព័ត៌មានថវិកាឡើយ

**៩៦.៥%**
ប្រជាពលរដ្ឋមិនធ្លាប់បានព្យាយាមស្វែងរកមើលព័ត៌មានថវិការបស់ឃុំ សង្កាត់ឡើយ

**៩៨.៥%**
ប្រជាពលរដ្ឋជឿថា ព័ត៌មានថវិកាឃុំ សង្កាត់គួរតែត្រូវបានរៀបចំឱ្យសាធារណជនទូទៅមានលទ្ធភាពទទួលបានច្រើន និងងាយយល់ជាងនេះ

## ផ្សេងៗ

ជាទូទៅ ប្រជាពលរដ្ឋភាគច្រើនយល់ស្របថា ថវិកាឃុំ សង្កាត់មានឥទ្ធិពលមកលើជីវិតរបស់ពួកគាត់។ ទោះយ៉ាងណាក្តី ប្រជាពលរដ្ឋតិចតួចប៉ុណ្ណោះដែលរាយការណ៍ថា ពួកគេពេញចិត្តទាំងស្រុងចំពោះដំណើរការថវិកាឃុំ សង្កាត់ ហើយមានប្រជាពលរដ្ឋកាន់តែតិចដែលជឿថា ដំណើរការថវិកានោះមានតម្លាភាព និងគណនេយ្យភាព។ ចំពោះបញ្ហាកង្វះតម្លាភាព និងគណនេយ្យភាព ប្រជាពលរដ្ឋមួយចំនួនតូចប៉ុណ្ណោះ បានរកឃើញមធ្យោបាយដើម្បីលើកឡើងនូវកង្វល់របស់ខ្លួនស្តីពីការមិនពេញចិត្តចំពោះដំណើរការថវិកាឃុំ សង្កាត់ ជូនដល់មន្ត្រីសាធារណៈ ឬតាមវិធីដទៃទៀតដោយជោគជ័យ។

**៨២.២%** ប្រជាពលរដ្ឋពុំធ្លាប់បានលើកឡើងនូវកង្វល់ទាក់ទងនឹងការមិនពេញចិត្តរបស់ខ្លួនទៅលើរបៀបដែលក្រុមប្រឹក្សាឃុំ សង្កាត់គ្រប់គ្រងចំណូល និងការបែងចែកថវិកាឃុំ សង្កាត់ ។

**៣៦.៨%** ប្រជាពលរដ្ឋជឿថា ដំណើរការថវិកាឃុំ សង្កាត់មានភាពត្រឹមត្រូវ និងតម្លាភាព។

**៥៣.៦%** ប្រជាពលរដ្ឋជឿថា ដំណើរការថវិកាឃុំ សង្កាត់មានតម្លាភាព និងស្មើភាព។

**១៤.៨%** ប្រជាពលរដ្ឋពេញចិត្តទាំងស្រុងចំពោះរបៀបដែលក្រុមប្រឹក្សាឃុំ សង្កាត់គ្រប់គ្រងចំណូល និងការបែងចែកថវិកាឃុំ សង្កាត់។

៣



# អនុសាសន៍សំខាន់ៗ

## សេចក្តីសន្និដ្ឋាន និងអនុសាសន៍ចំពោះរដ្ឋាភិបាលថ្នាក់ជាតិ

### ការឆ្លើយតបចំពោះបញ្ហាចំណេះដឹងទាបអំពីថវិកា និងដំណើរការថវិកា

ជាទូទៅ ការយល់ដឹងរបស់សាធារណជនអំពីដំណើរការថវិកា គឺមានកម្រិតទាប។ មានប្រជាពលរដ្ឋត្រឹមតែ ០.៣% ក្នុងចំណោមសំណាកនៃការស្ទង់មតិនេះ ដែលអាចប្រាប់បានយ៉ាងត្រឹមត្រូវអំពីទំហំថវិកាជាតិ។ បន្ថែមលើនេះទៀត ភាពរយនៃប្រជាពលរដ្ឋ ដែលអាចប្រាប់អំពីស្ថាប័នរដ្ឋដែលទទួលបន្ទុកក្នុងការរៀបចំសេចក្តីព្រាងថវិកា មានត្រឹមតែ ៥%ឬតិចជាងនេះ។ ហេតុនេះ រាជរដ្ឋាភិបាលគួរតែខិតខំប្រឹងប្រែងឱ្យខ្លាំងថែមទៀត ដើម្បីបញ្ជ្រាបព័ត៌មានដល់សាធារណជនអំពីដំណើរការថវិកាថ្នាក់ជាតិ។ ការបង្កើននូវចំណេះដឹងរបស់សាធារណជន តាមវិធីនេះ នឹងមិនត្រឹមតែអាចបង្កើតភាពជាម្ចាស់ការកាន់តែច្រើនទាក់ទងនឹងការដំណើរថវិកាទូទៅប៉ុណ្ណោះទេ ប៉ុន្តែក៏ជាមធ្យោបាយដ៏ចាំបាច់មួយ ដើម្បីសម្រេចបាននូវអនុសាសន៍ដទៃទៀតដែលត្រូវបានលើកឡើងនៅក្នុងរបាយការណ៍នេះផងដែរ។

### បង្កើនការរួមបញ្ចូលក្នុងដំណើរការថវិកា និងការបែងចែកថវិកា ជាពិសេសសម្រាប់ស្ត្រី

ថ្វីបើការយល់ដឹងរបស់សាធារណជនអំពីថវិកាជាតិ ជាទូទៅមានកម្រិតទាបក្តី ប៉ុន្តែចំណេះដឹងរបស់ស្ត្រីអំពីថវិកាជាតិ គឺមានកម្រិតទាបជាងបុរសជានិច្ច។ ស្ត្រីត្រឹមតែ ២.១% ប៉ុណ្ណោះ ដែលអាចឆ្លើយសំណួរអំពីថវិកាជាតិបានយ៉ាងហោចណាស់មួយបានត្រឹមត្រូវ បើប្រៀបធៀបជាមួយបុរសគឺមាន ១១.៥%។ កម្រិតនៃចំណេះដឹងរបស់ស្ត្រីដែលទាបជាងបុរសនោះ គឺជានិន្នាការមួយដែលស្តែងចេញនៅក្នុងគ្រប់ទិដ្ឋភាពទាំងអស់នៃដំណើរការថវិកា ហើយទំនងជាបណ្តាលមកពីកត្តាផ្សេងៗដូចជា ការមិនសូវគិតគូរដល់ស្ត្រីចំពោះការទទួលបានការអប់រំ ក៏ដូចជា តួនាទីក្នុងរដ្ឋបាលសាធារណៈជាដើម ដែលរាជរដ្ឋាភិបាលអាចកែតម្រូវបានតាមរយៈការចុះផ្សព្វផ្សាយអប់រំសាធារណជនឱ្យកាន់តែទូលំទូលាយថែមទៀត។ ការងារនេះចាំបាច់ត្រូវតែជាគោលដៅគន្លឹះ សម្រាប់គោលនយោបាយរបស់រដ្ឋាភិបាល ពាក់ព័ន្ធនឹងការផ្សព្វផ្សាយព័ត៌មានថវិកានាពេលអនាគត។

### ផ្តល់លទ្ធភាពកាន់តែប្រសើរដើម្បីទទួលបានព័ត៌មានថវិកាឱ្យទាន់ពេលវេលា និងច្បាស់លាស់

បើទោះជា ការយល់ដឹងរបស់សាធារណជនអំពីដំណើរការថវិកាជាតិមានកម្រិតទាបក៏ដោយ លទ្ធភាពក្នុងការទទួលបានព័ត៌មានពាក់ព័ន្ធនឹងថវិកាជាតិ ក៏ជាហេតុគួរឱ្យបារម្ភកាន់តែខ្លាំងថែមទៀត។ មានត្រឹមតែ ០.១% ក្នុងចំណោមសំណាកនៃការស្ទង់មតិនេះ ដែលធ្លាប់បានឃើញឯកសាររដ្ឋាភិបាលស្តីពីថវិកា ហើយស្រដៀងគ្នានេះដែរ ប្រជាពលរដ្ឋត្រឹមតែ ១.១% ប៉ុណ្ណោះ ដែលធ្លាប់ព្យាយាមស្វែងរកមើលឯកសារស្តីពីថវិកា។ ជាងនេះទៅទៀត ៦៣.៤%នៃអ្នកផ្តល់ចម្លើយបង្ហាញថា លទ្ធភាពក្នុងការទទួលបានព័ត៌មានថវិកាគឺ "មានសារៈសំខាន់ខ្លាំងណាស់" ដូចនេះរដ្ឋាភិបាលថ្នាក់ជាតិត្រូវតែបង្កើនលទ្ធភាពក្នុងការទទួលបានព័ត៌មានស្តីពីថវិកា សម្រាប់ប្រជាពលរដ្ឋទូទៅ ដើម្បីបំពេញទៅតាមការចង់បានដ៏ខ្លាំងរបស់ពួកគាត់ ទាក់ទងនឹងថវិកា និងហិរញ្ញវត្ថុជាតិ។ យ៉ាងណាក៏ដោយ ការបិតផ្សាយព័ត៌មានគឺមិនគ្រប់គ្រាន់ឡើយ។ រដ្ឋាភិបាលក៏ត្រូវតែពិចារណាផងដែរទៅលើរបៀបដែលព័ត៌មានទាំងនេះត្រូវបានរៀបចំ និងបង្ហាញ ក៏ដូចជារបៀបដែលវាត្រូវបានចែកចាយ និងផ្សព្វផ្សាយជាដើម ដើម្បីធានាបាននូវការបញ្ជ្រាបបានទូលំទូលាយ និងលទ្ធភាពក្នុងការទទួលបានព័ត៌មានច្រើន។

**បង្កើនការយល់ដឹងអំពីចំណូលថវិកា និងពន្ធ**

ឧបសគ្គដ៏សំខាន់មួយសម្រាប់រដ្ឋាភិបាលថ្នាក់ជាតិដើម្បីសម្រេចបាននូវតម្លាភាពថវិកា គឺការយល់ដឹងទាបរបស់សាធារណជន អំពីចំណូលថវិកា និងពន្ធ។ លទ្ធផលនៃការស្ទង់មតិនេះបង្ហាញថា ជំនួយបរទេសគឺនៅតែជាប្រភពចំណូលថវិកាដែលប្រជាពលរដ្ឋដឹងច្បាស់ជាងគេបំផុត ហើយប្រជាពលរដ្ឋ ៨១% ពុំដឹងអំពីកាតព្វកិច្ចបង់ពន្ធណាមួយរបស់ខ្លួនសោះឡើយ។ ច្បាស់ណាស់ថា ចំណុចដែលបានលើកឡើងនេះបង្កើតជាបញ្ហាមួយដែលមិនត្រឹមតែទាក់ទងនឹងតម្លាភាព និងគណនេយ្យភាពប៉ុណ្ណោះទេ ប៉ុន្តែវាក៏ពាក់ព័ន្ធផងដែរចំពោះកិច្ចខិតខំប្រឹងប្រែងរបស់រដ្ឋាភិបាលក្នុងការប្រមូលចំណូលថវិការដ្ឋផងដែរ។ ហេតុនេះ កិច្ចខិតខំប្រឹងប្រែងឱ្យកាន់តែច្រើនថែមទៀត ដើម្បីបង្កើនការយល់ដឹងរបស់សាធារណជនអំពីពន្ធ និងការប្រមូលចំណូលថវិកា គឺសំខាន់ខ្លាំងណាស់។

## សេចក្តីសន្និដ្ឋាន និងអនុសាសន៍ចំពោះរដ្ឋបាលថ្នាក់ក្រោមជាតិ

**បង្កើនលទ្ធផលពីកំណែទម្រង់វិមជ្ឈការ និងសហវិមជ្ឈការឱ្យបានច្រើនជាអតិបរមាដើម្បីបង្កើនតម្លាភាព គណនេយ្យភាព និងលទ្ធភាពក្នុងការទទួលបានព័ត៌មាន**

វិមជ្ឈការ និងសហវិមជ្ឈការបានធ្វើឱ្យរដ្ឋាភិបាលខិតកាន់តែកៀកជាមួយប្រជាពលរដ្ឋ។ ទោះយ៉ាងណាក្តី នៅមានការងារដ៏សំខាន់ជាច្រើនថែមទៀតដែលត្រូវធ្វើ។ ប្រជាពលរដ្ឋ ៦៥% ពុំដែលស្វែងរកព័ត៌មានថវិកា ហើយប្រជាពលរដ្ឋច្រើនជាង ៧៥% "មិនដឹងទាល់តែសោះ" អំពីផែនការអភិវឌ្ឍ កម្មវិធីវិនិយោគ និងថវិកាឃុំ សង្កាត់ ហើយប្រជាពលរដ្ឋតិចជាង១ភាគ១០ ពោលគឺត្រឹមតែ ៩.៨% ដែលធ្លាប់បានទទួលព័ត៌មានពីអាជ្ញាធរឃុំ សង្កាត់អំពីការបិទផ្សាយព័ត៌មានថវិកា។ ហេតុនេះ មានការងារច្រើនទៀតដែលចាំបាច់ត្រូវធ្វើដើម្បីបង្កើនគណនេយ្យភាពរបស់រដ្ឋបាលថ្នាក់មូលដ្ឋានចំពោះម្ចាស់ឆ្នោតរបស់ខ្លួន ដើម្បីស្ថាបនាបន្ថែមទៀតលើកិច្ចខិតខំប្រឹងប្រែងរបស់ខ្លួនកន្លងមក។

**ផ្តល់គណនេយ្យភាពកាន់តែប្រសើរសម្រាប់ប្រជាពលរដ្ឋរស់នៅតំបន់ទីប្រជុំជន**

ភាពខុសគ្នាផ្នែកភូមិសាស្ត្ររវាងតំបន់ជនបទ និងទីប្រជុំជន គឺជាគន្លឹះក្នុងការស្វែងយល់អំពីតម្លាភាព និងគណនេយ្យភាពនៃថវិកាសាធារណៈ។ ជាទូទៅ ប្រជាពលរដ្ឋនៅតំបន់ទីប្រជុំជនបង្ហាញនូវកម្រិតនៃការយល់ដឹងខ្ពស់អំពីដំណើរការថវិកាថ្នាក់ជាតិ តួយ៉ាងប្រជាពលរដ្ឋ ១៣.១% អាចឆ្លើយសំណួរស្តីពីថវិកាថ្នាក់ជាតិយ៉ាងហោចណាស់មួយបានត្រឹមត្រូវ បើប្រៀបធៀបទៅនឹងប្រជាពលរដ្ឋនៅជនបទមានត្រឹមតែ ៥.១%។ ប៉ុន្តែ កម្រិតនៃចំណេះដឹងនេះពុំបានឆ្លុះបញ្ចាំងអំពីការចូលរួមនោះឡើយ។ ចំណេះដឹងអំពីដំណើរការថវិកានៅថ្នាក់ឃុំ សង្កាត់មានកម្រិតទាបសម្រាប់ប្រជាពលរដ្ឋនៅតំបន់ទីប្រជុំជន ជាងប្រជាពលរដ្ឋនៅទីជនបទ ពោលគឺមានប្រជាពលរដ្ឋនៅតំបន់ទីប្រជុំជនត្រឹមតែ ១៥.៣% ប៉ុណ្ណោះ ដែលអាចឆ្លើយបានត្រឹមត្រូវចំពោះសំណួរចំនួនពីរ ឬច្រើនជាងនេះ បើប្រៀបធៀបនឹងប្រជាពលរដ្ឋនៅជនបទមាន ១៩.១% ។ និន្នាការនេះបានឆ្លុះបញ្ចាំងតាមរយៈសូចនាករជាច្រើនសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិ ដែលស្នើឱ្យមានកិច្ចខិតខំប្រឹងប្រែងឱ្យខ្លាំងបន្ថែមទៀត ដើម្បីលើកទឹកចិត្តឱ្យមានការចូលរួមកាន់តែច្រើន នៅក្នុងដំណើរថវិកាថ្នាក់មូលដ្ឋាននៅតាមតំបន់ទីប្រជុំជន។

**សម្របសម្រួលឱ្យមានការចូលរួមកាន់តែច្រើនពីសាធារណជន**

ការចូលរួមក្នុងកម្រិតទាបរបស់សាធារណជននៅក្នុងដំណើរថវិកាថ្នាក់មូលដ្ឋាន មិនមែនគ្រាន់តែជាបញ្ហាដែលកើតឡើងចំពោះតែប្រជាជននៅតំបន់ទីប្រជុំជនឡើយ។ ក្នុងចំណោមសំណាកនៃការស្ទង់មតិនេះ ប្រជាពលរដ្ឋ ៨៨% គិតថា ការចូលរួមរបស់សាធារណជនកាន់តែច្រើននឹងធ្វើឱ្យមានគណនេយ្យភាពកាន់តែប្រសើរ ហើយប្រជាពលរដ្ឋលើសពី ៩១% និយាយថាគុណភាពនៃសេវានានានឹងប្រសើរជាងមុន តាមរយៈការចូលរួមកាន់តែច្រើនផងដែរ។ ទោះជាយ៉ាងណាក្តី ក្នុងទិដ្ឋភាពជាក់ស្តែង ការចូលរួមនៅតែមានកម្រិតទាប។ ចំពោះបុគ្គលដែលពុំបាន

ចូលរួមក្នុងដំណើរការទាំងនោះអះអាងថា កង្វះការលើកទឹកចិត្តឱ្យចូលរួម និងកង្វះខាតនៃការផ្សព្វផ្សាយព័ត៌មានអំពីឱកាសក្នុងការចូលរួម គឺជាកត្តារាំងស្ទះពួកគាត់មិនអាចចូលរួមបាន។ រដ្ឋបាលថ្នាក់មូលដ្ឋានចាំបាច់ត្រូវកែលម្អការងារផ្សព្វផ្សាយនៅតាមមូលដ្ឋានរបស់ខ្លួន ដើម្បីធ្វើឱ្យមានការចូលរួមរបស់សាធារណជនឱ្យកាន់តែច្រើននៅក្នុងសេចក្តីសម្រេចពាក់ព័ន្ធនឹងថវិកា។

## បង្កើនតម្លាភាពចំពោះបញ្ហានយោបាយ និងថវិកានៅមូលដ្ឋាន

វាជាការចាំបាច់ ដែលត្រូវញែកពីគ្នាឱ្យច្បាស់លាស់ថែមទៀត រវាងការគាំទ្រផ្នែកនយោបាយ និងផែនការអភិវឌ្ឍនៅមូលដ្ឋាន។ បច្ចុប្បន្ន ប្រជាពលរដ្ឋជាង ៦០% អាចរំឭកនូវករណីដែលថវិកាសម្រាប់ផែនការអភិវឌ្ឍនៅមូលដ្ឋានអាចត្រូវបានប្រើប្រាស់ដើម្បីទទួលបានការគាំទ្រផ្នែកនយោបាយ។ បន្ថែមលើនេះទៀត ប្រជាពលរដ្ឋស្មើរ ១ ភាគ ៣ "មិនដឹងច្បាស់លាស់សោះ" ថាតើគម្រោងអភិវឌ្ឍណាដែលទទួលថវិការបស់រដ្ឋ និងគម្រោងអភិវឌ្ឍណាដែលទទួលថវិការបស់គណបក្សនយោបាយ។ ដូច្នេះ ចាំបាច់ត្រូវតែមានកិច្ចខិតខំប្រឹងប្រែងបន្ថែមទៀត ក្នុងការបង្ហាញឱ្យច្បាស់ ដើម្បីធ្វើឱ្យការយល់ឃើញរបស់សាធារណជន ចំពោះតម្លាភាពនៃដំណើរថវិកាថ្នាក់មូលដ្ឋាន មានភាពប្រសើឡើង។

**Transparency International Cambodia**
#3, Street 390, Sangkat BoengKengkang 3, Khan Chamkarmorn,
Phnom Penh, Kingdom of Cambodia
Phone: (+855) 23 21 44 30/ 23 21 42 11

Website: www.ticambodia.org
Global website: www.transparency.org